**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០២៣ សហវ.

# សេចក្តីសម្រេច
## ស្តីពី
## យន្តការ និងនីតិវិធី នៃការអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ០២០ សហវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ច ទទួលបន្ទុករៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយស្តីពីអន្តរាគមន៍ជំនួយសង្គម ដើម្បីជួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ដោយសារជំងឺកូវីដ-១៩ ក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦១ សសរ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ចាប់ពី ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ តទៅ ដោយជំនួសមកវិញនូវវិធានការថ្មី សំដៅបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់គណៈអភិបាលរាជធានីភ្នំពេញ សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងរបស់គណៈអភិបាលខេត្តកណ្តាល សម្រាប់ភូមិសាស្ត្រក្រុងតាខ្មៅ
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

សេចក្តីសម្រេចនេះមានគោលបំណងកំណត់អំពីយន្តការ និងនីតិវិធី នៃការដាក់ឱ្យអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព ដែលស្ថិតក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ នៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ, និងជំនួយសង្គមជាសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាពនិងសម្រាប់គ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ នៅទូទាំងប្រទេស។

**ប្រការ ២.-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរ ដូចខាងក្រោម÷

- គ្រួសារមានការលំបាកផ្នែកជីវភាព និងកម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាស

នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ក្នុងភូមិសាស្ត្រដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ។

- គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព, កម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលឆ្លងជំងឺកូវីដ-១៩ និងនៅក្រៅតំបន់អនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ នៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ក្នុងភូមិសាស្ត្រទូទាំងប្រទេស។

**ប្រការ ៣.-**

**គ្រួសារមានការលំបាកផ្នែកជីវភាព** សំដៅដល់គ្រួសារមានកម្រិតជីវភាពទាប និងមានការលំបាកផ្នែកជីវភាពដែលរងផលប៉ះពាល់ដោយព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ និងរស់នៅក្នុងតំបន់ដែលបានអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និងត្រូវបានកំណត់អត្តសញ្ញាណ ដោយយន្តការរបស់ក្រសួងផែនការ ដែលមានចែងក្នុងសេចក្តីសម្រេចនេះ។

**គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព** សំដៅដល់គ្រួសារមានកម្រិតជីវភាពទាប និងមានការលំបាកផ្នែកជីវភាព ដែលមានសមាជិកឆ្លងជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដែលស្ថិតក្នុងបញ្ជីផ្លូវការរបស់រដ្ឋបាលរាជធានី-ខេត្ត។

**កម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប** សំដៅដល់កម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលរស់នៅក្នុងតំបន់ដែលបានអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ, និងកម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលឆ្លងជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ និងនៅក្រៅតំបន់អនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ, ដែលត្រូវបានកំណត់អត្តសញ្ញាណ ដោយយន្តការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានចែងក្នុងសេចក្តីសម្រេចនេះ។

គ្រួសារមានបណ្ណសមធម៌ ដែលកំពុងទទួលការឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សំដៅដល់គ្រួសារប្រជាពលរដ្ឋដែលមានបណ្ណសមធម៌ ប្រភេទ "ក្រ-១" និង "ក្រ-២" ដែលកំពុងបន្តទទួលបានជំនួយឧបត្ថម្ភជាសាច់ប្រាក់សម្រាប់ទ្រទ្រង់ជីវភាព ជារៀងរាល់ខែ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ។

គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ សំដៅដល់គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដែលស្ថិតក្នុងបញ្ជីផ្លូវការរបស់ក្រសួងសុខាភិបាល និងមានលិខិតមរណភាពផ្លូវការ។

## ជំពូកទី ២

## ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព

**ប្រការ ៤.-**

ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋ មានការលំបាកផ្នែកជីវភាព ដែលស្ថិតក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និងដែលត្រូវបានកំណត់អត្តសញ្ញាណក្រោមយន្តការ ដូចមានចែងក្នុងសេចក្តីសម្រេចនេះ, ត្រូវបានកំណត់ ដូចខាងក្រោម÷

| ទំហំគ្រួសារ | ថ្លៃស្បៀងអាហារ (រៀល) | ថ្លៃទឹកស្អាត២ ខែ (រៀល) | ថ្លៃអគ្គិសនី ២ ខែ (រៀល) | ឧបត្ថម្ភសាច់ប្រាក់សរុប (រៀល) |
|---|---|---|---|---|
| ១ នាក់ | ១០០ ០០០ | ១៨ ០០០ | ៣៨ ០០០ | ១៥៦ ០០០ |
| ២ ទៅ ៣ នាក់ | ១១៣ ៥០០ | ៤៤ ៨០០ | ៨៥ ៤០០ | ២៤៣ ៧០០ |
| ៤ នាក់ឡើង | ១២៧ ០០០ | ៦២ ០០០ | ១២២ ០០០ | ៣១១ ០០០ |

គ្រួសារមានបណ្ណសមធម៌ ដែលកំពុងទទួលការឧបត្ថម្ភ ជារៀងរាល់ខែ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ មិនទទួលបានការឧបត្ថម្ភនេះបន្ថែមទៀតទេ។

**ប្រការ ៥.-**

កម្មករ-និយោជិត បម្រើការងារនៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប នៅក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ត្រូវទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ចំនួន ១៦០ ០០០ (ដប់ប្រាំមួយម៉ឺន) រៀល តែម្តងគត់។

## ជំពូកទី ៣
## ជំនួយសង្គមជាសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងសម្រាប់គ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

**ប្រការ ៦.-**

ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ត្រូវបានកំណត់ ដូចខាងក្រោម÷

| ទំហំគ្រួសារ | ថ្លៃស្បៀងអាហារ (រៀល) | ថ្លៃទឹកស្អាត ២ ខែ (រៀល) | ថ្លៃអគ្គិសនី ២ ខែ (រៀល) | ឧបត្ថម្ភសាច់ប្រាក់សរុប (រៀល) |
|---|---|---|---|---|
| ១ នាក់ | ១០០ ០០០ | ១៨ ០០០ | ៣៨ ០០០ | ១៥៦ ០០០ |
| ២ ទៅ ៣ នាក់ | ១១៣ ៥០០ | ៤៤ ៨០០ | ៨៥ ៤០០ | ២៤៣ ៧០០ |
| ៤ នាក់ឡើង | ១២៧ ០០០ | ៦២ ០០០ | ១២២ ០០០ | ៣១១ ០០០ |

កម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលឆ្លងជំងឺកូវីដ-១៩ និងនៅក្រៅតំបន់អនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្ដាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ត្រូវទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ចំនួន ១៦០ ០០០ រៀល តែមួយលើកគត់។

គ្រួសារដែលទទួលបានការឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ៤ នៃសេចក្ដីសម្រេចនេះ និងគ្រួសារមានបណ្ណសមធម៌ដែលកំពុងទទួលការឧបត្ថម្ភ ជារៀងរាល់ខែ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១, និងកម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលទទួលបានការឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ៥ នៃសេចក្ដីសម្រេចនេះ, មិនទទួលបានការឧបត្ថម្ភនេះបន្ថែមទៀតទេ។

**ប្រការ ៧.-**

ការឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវបានកំណត់ ដូចខាងក្រោម÷

| ទំហំគ្រួសារ | ថ្លៃស្បៀងអាហារ (រៀល) | ថ្លៃទឹកស្អាត ៥ ខែ (រៀល) | ថ្លៃអគ្គិសនី ៥ ខែ (រៀល) | ឧបត្ថម្ភសាច់ប្រាក់សរុប (រៀល) |
|---|---|---|---|---|
| ១ នាក់ | ៣០០ ០០០ | ៤៥ ០០០ | ៩៥ ០០០ | ៤៤០ ០០០ |
| ២ ទៅ ៣ នាក់ | ៣០០ ០០០ | ១១២ ០០០ | ២១៣ ៥០០ | ៦២៥ ៥០០ |
| ៤ នាក់ឡើង | ៣០០ ០០០ | ១៥៥ ០០០ | ៣០៥ ០០០ | **៧៦០ ០០០** |

គ្រួសារដែលទទួលបានការឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ៤ និងប្រការ ៦ នៃសេចក្តីសម្រេចនេះ, គ្រួសារមានបណ្ណសមធម៌ ដែលកំពុងទទួលការឧបត្ថម្ភ ជារៀងរាល់ខែពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, និងគ្រួសាររបស់កម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលទទួលបានការឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ៥ និងប្រការ ៦ នៃសេចក្តីសម្រេចនេះ ដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១, ត្រូវទទួលបានការឧបត្ថម្ភនេះបន្ថែម។

## ជំពូកទី ៤
## យន្តការ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ

**ប្រការ ៨.-**

យន្តការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ ត្រូវអនុវត្តដោយក្រសួងផែនការ សហការជាមួយរដ្ឋបាលឃុំ សង្កាត់ និងគាំទ្រដោយអ្នកស្ម័គ្រចិត្តពីសហភាពសហព័ន្ធយុវជនកម្ពុជា ឬអ្នកស្ម័គ្រចិត្តផ្សេងទៀត និងដោយប្រើប្រាស់យន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដែលមានស្រាប់ ដោយរៀបចំកម្រងសំណួរ, លក្ខណៈវិនិច្ឆ័យ និងប្រព័ន្ធបូកពិន្ទុដោយឡែក នៅក្នុងប្រព័ន្ធអែប (App)។

ក្រសួងផែនការត្រូវរៀបចំសេចក្តីណែនាំស្តីពីនីតិវិធីនៃការស្រង់បញ្ជីឈ្មោះ ការសម្ភាស និងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ និងកិច្ចសហការជាមួយរដ្ឋបាលឃុំ សង្កាត់ ក្នុងក្របខណ្ឌនៃយន្តការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ។

**ប្រការ ៩.-**

រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំបញ្ជីឈ្មោះគ្រួសារគោលដៅ និងធ្វើការសម្ភាសតាមខ្នងផ្ទះ ឬតាមប្រព័ន្ធទូរសព្ទ ដោយប្រើប្រាស់ប្រព័ន្ធអែបកំណត់អត្តសញ្ញាណគ្រួសារគោលដៅរបស់ក្រសួងផែនការ។

**ប្រការ ១០.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តការកំណត់អត្តសញ្ញាណកម្មករ-និយោជិតបម្រើការងារនៅតាមរោងចក្រ-សហគ្រាស នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលស្ថិតក្រោមវិសាលភាពនៃសេចក្តីសម្រេចនេះ។

## ជំពូកទី ៥

## យន្តការ និងនីតិវិធីនៃការបើកផ្តល់

**ប្រការ ១១.-**

ការបើកផ្តល់សាច់ប្រាក់ក្រោមកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវអនុវត្តជាការឧបត្ថម្ភសាច់ប្រាក់សរុបចំនួន ០១ (មួយ) លើកគត់។

**ប្រការ ១២.-**

ការបើកផ្តល់ជូនគ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណដោយក្រសួងផែនការ ក្រោមយន្តការដូចមានចែងក្នុងសេចក្តីសម្រេចនេះ ត្រូវអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយប្រើប្រាស់យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមរយៈធនាគារវីង។

**ប្រការ ១៣.-**

គ្រួសារគោលដៅដែលជាអ្នកទទួលផល អាចដកប្រាក់ឧបត្ថម្ភ នៅតាមបញ្ជរវីងណាមួយ នៅគ្រប់ទីកន្លែង ឬ តាមរយៈប្រព័ន្ធអែបស្វ័យប្រវត្តរបស់ធនាគារវីង។ សម្រាប់ករណីគ្រួសារប្រជាពលរដ្ឋមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩, ឃុំ សង្កាត់អាចសហការជាមួយភ្នាក់ងារវីង ដើម្បីបើកសាច់ប្រាក់ដល់ផ្ទះ។

**ប្រការ ១៤.-**

ការបើកផ្តល់ជូនកម្មករ-និយោជិតបម្រើការងារនៅតាមរោងចក្រ-សហគ្រាស នៅក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង និងកាបូប នៅក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និងកម្មករ-និយោជិតបម្រើការងារ នៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលឆ្លងជំងឺកូវីដ-១៩ និងនៅក្រៅតំបន់អនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ, ត្រូវអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយប្រើប្រាស់យន្តការ ដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករ-និយោជិតនៅពេលព្យួរកិច្ចសន្យាការងារ តាមរយៈធនាគារវីង។

## ជំពូកទី ៦
## ក្រសួង ស្ថាប័នដឹកនាំ និងចុះបញ្ជីអនុវត្តកម្មវិធី

**ប្រការ ១៥.-**

កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយសម្របសម្រួលរវាងក្រសួង-ស្ថាប័នចំណុះ និងមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាលេខាធិការ។

**ប្រការ ១៦.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការបើកផ្តល់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- រៀបចំសេចក្តីណែនាំ ស្តីពីនីតិវិធីនៃការបើកផ្តល់, លិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង និងការអនុវត្តការបើកផ្តល់
- រៀបចំបង្កើតមុខងារនៃប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រៀបចំផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការអនុវត្តការបើកផ្តល់
- រៀបចំការបណ្តុះបណ្តាលដល់អ្នកអនុវត្តកម្មវិធី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បញ្ជូនទិន្នន័យប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារគោលដៅនីមួយៗ ទៅស្ថាប័នបើកផ្តល់ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភទៅគណនីរបស់អ្នកទទួលផល
- ជូនព័ត៌មាន និងអប់រំផ្សព្វផ្សាយអំពីកម្មវិធី និងអំពីការបើកផ្តល់ ដល់មន្ត្រីពាក់ព័ន្ធ ឃុំ សង្កាត់ និងគ្រួសារគោលដៅ
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងការអនុវត្តការបើកផ្តល់
- សហការជាមួយស្ថាប័នបើកផ្តល់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហា ជាយថាហេតុ
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**ប្រការ ១៧.-**

ក្រសួងផែនការ ជាស្ថាប័នទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- រៀបចំសេចក្តីណែនាំស្តីពីនីតិវិធីនៃការស្រង់បញ្ជីឈ្មោះ និងការសម្ភាស និងកំណត់អត្តសញ្ញាណគ្រួសារគោលដៅ
- សម្របសម្រួលជាមួយរដ្ឋបាលរាជធានី ខេត្ត រៀបចំក្រុមសម្ភាស នៅឃុំ សង្កាត់
- រៀបចំ និងសម្របសម្រួលអ្នកស្ម័គ្រចិត្ត សម្រាប់ការសម្ភាស នៅថ្នាក់ឃុំ សង្កាត់
- បណ្តុះបណ្តាលអ្នកសម្ភាសនៅឃុំ សង្កាត់
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ប្រព័ន្ធវែប និងប្រព័ន្ធទិន្នន័យគ្រួសារគោលដៅ
- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ ដែលមានបណ្ណសមធម៌ កំពុងទទួលបានការឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីជាមូលដ្ឋានសម្រាប់ឃុំ សង្កាត់ ក្នុងការដកចេញ ពេលកំណត់អត្តសញ្ញាណ
- ពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យគ្រួសារគោលដៅ ដែលបានសម្ភាសរួច
- រៀបចំ និងបញ្ជូនទិន្នន័យគ្រួសារគោលដៅដែលត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់ និងត្រឹមត្រូវតាមប្រព័ន្ធព័ត៌មានវិទ្យាAPI ទៅក្រសួងដែលទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការបើកផ្តល់
- សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាជាយថាហេតុ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**ប្រការ ១៨.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាស្ថាប័នទទួលបន្ទុកអនុវត្តការកំណត់អត្តសញ្ញាណ និងការបើកផ្តល់ជូនកម្មករ-និយោជិត មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- រៀបចំសេចក្តីណែនាំ ស្តីពីនីតិវិធីនៃការប្រមូលបញ្ជីឈ្មោះ និងកំណត់អត្តសញ្ញាណកម្មករ-និយោជិតគោលដៅ
- រៀបចំសេចក្តីណែនាំ ស្តីពីនីតិវិធីនៃការបើកផ្តល់, លិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង និងការអនុវត្តការបើកផ្តល់
- រៀបចំបង្កើតមុខងារនៃប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីប្រមូល និងគ្រប់គ្រងទិន្នន័យកម្មករ-និយោជិតគោលដៅ
- ពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យកម្មករ-និយោជិតគោលដៅ ដែលទទួលបាន
- បញ្ជូនទិន្នន័យកម្មករ-និយោជិតគោលដៅ ទៅស្ថាប័នបើកផ្តល់ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភទៅគណនីរបស់អ្នកទទួលផល
- សហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហា ជាយថាហេតុ
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**ប្រការ ១៩.-**

ក្រសួងសុខាភិបាល ជាស្ថាប័នទទួលបន្ទុកផ្តល់ព័ត៌មានអំពីអត្តសញ្ញាណអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំអំពីអត្តសញ្ញាណអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ជូនក្រសួងដែលទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការបើកផ្តល់ ដែលក្នុងនោះរួមមាន ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានបច្ចុប្បន្ន (ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ) និងលេខទូរសព្ទសមាជិកគ្រួសារសព
- ថតចម្លងលិខិតបញ្ជាក់មរណភាពរបស់អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩
- កំណត់អ្នកទទួលបន្ទុកទំនាក់ទំនងដើម្បីផ្តល់ព័ត៌មានរបស់អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី និងដោះស្រាយបញ្ហាពាក់ព័ន្ធ ជាយថាហេតុ។

**ប្រការ ២០.-**

ក្រសួងមហាផ្ទៃ ជាស្ថាប័នទទួលបន្ទុកសម្របសម្រួល និងជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី និងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ និងផ្តល់កិច្ចសហការក្នុងការពិនិត្យតាមដាន និងគាំទ្រការអនុវត្តកម្មវិធី។

រដ្ឋបាលរាជធានី ខេត្ត ជាស្ថាប័នដឹកនាំការអនុវត្តក្នុងការប្រមូលទិន្នន័យគ្រួសារតាមទិន្នន័យប៉ាន់ប្រមាណ និងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ ដោយមានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរផែនការ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាលេខាធិការ និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ ក្នុងការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ ដោយជូនព័ត៌មានអប់រំផ្សព្វផ្សាយអំពីកម្មវិធី សហការក្នុងការគាំទ្រដល់ការកសាងសមត្ថភាព និងផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន វាយតម្លៃការអនុវត្តកម្មវិធី និងដោះស្រាយបញ្ហា ជាយថាហេតុពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ប្រការ ២១.-**

រដ្ឋបាលឃុំ សង្កាត់ ជាស្ថាប័នចូលរួមអនុវត្តការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ និងសម្របសម្រួលការបើកផ្តល់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- រៀបចំបញ្ជីឈ្មោះក្រុមអ្នកសម្ភាសរបស់ឃុំ សង្កាត់ដោយមានក្រុមការងារកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងអ្នកស្ម័គ្រចិត្ត ផ្អែកតាមតម្រូវការជាក់ស្តែង
- ស្រង់បញ្ជីឈ្មោះគ្រួសារគោលដៅ ដោយផ្អែកតាមទិន្នន័យប៉ាន់ស្មាន
- អនុម័តចំនួនគ្រួសារដែលត្រូវសម្ភាស តាមភូមិនីមួយៗ

- ដឹកនាំការសម្ភាស និងបញ្ចូលលទ្ធផលសម្ភាស តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា
- ជូនដំណឹងដល់គ្រួសារគោលដៅ អំពីលទ្ធផលនៃការសម្ភាស និងការបើកផ្តល់
- រាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**ប្រការ ២២.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ក្នុងការពិនិត្យ និងផ្តល់យោបល់លើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី និងសហការក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហា ជាយថាហេតុ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ប្រការ ២៣.-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាស្ថាប័នទទួលបន្ទុកសម្របសម្រួលការអនុវត្តកម្មវិធី មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួល និងសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដាន និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- រៀបចំ សម្របសម្រួល និងអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធី
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ជូនរាជរដ្ឋាភិបាល។

**ប្រការ ២៤.-**

សហភាពសហព័ន្ធយុវជនកម្ពុជា ជាស្ថាប័នទទួលបន្ទុកចូលរួមសហការសម្របសម្រួលការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីកំណត់អត្តសញ្ញាណគ្រួសារគោលដៅ ដែលរៀបចំដោយក្រសួងផែនការ
- ចូលរួមសម្របសម្រួល និងសហការជាមួយឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធក្នុងការស្រង់បញ្ជីឈ្មោះ ការសម្ភាស និងការបញ្ចូលទិន្នន័យក្រុមគ្រួសារគោលដៅ
- ចូលរួមសម្របសម្រួល និងសហការជាមួយឃុំ សង្កាត់ ក្នុងការជូនដំណឹងដល់គ្រួសារគោលដៅអំពីលទ្ធផលនៃការសម្ភាស និងការបើកផ្តល់
- ផ្តល់កិច្ចសហការក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

## ជំពូកទី ៧
## ថវិកាសម្រាប់អនុវត្តកម្មវិធីជំនួយសង្គម

**ប្រការ ២៥.-**

កញ្ចប់ថវិកាសម្រាប់ការបើកផ្តល់ដែលអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

កញ្ចប់ថវិកាសម្រាប់ការបើកផ្តល់ដែលអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ២៦.-**

ថវិកាសម្រាប់កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវបើកផ្តល់ជាបុរេប្រទានដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុវត្តទូទាត់ជម្រះចំណាយតាមក្រោយ។

**ប្រការ ២៧.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំសំណើសុំបុរេប្រទាន ដោយផ្អែកលើទិន្នន័យទទួលបានពីការកំណត់អត្តសញ្ញាណគ្រួសារគោលដៅរបស់ក្រសួងមហាផ្ទៃ និងទិន្នន័យអ្នកឆ្លងជំងឺកូវីដ-១៩ និងអ្នកស្លាប់ដោយជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល និងរដ្ឋបាលរាជធានី-ខេត្ត ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ទៅតាមយន្តការរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយប្រើប្រាស់កញ្ចប់ថវិកាជំនួយសង្គម។

**ប្រការ ២៨.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំសំណើសុំបុរេប្រទាន ដោយផ្អែកលើទិន្នន័យទទួលបានពីការកំណត់អត្តសញ្ញាណកម្មករ-និយោជិតគោលដៅ និងកម្មករ-និយោជិតឆ្លងជំងឺកូវីដ-១៩ ផ្លូវការ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ទៅតាមយន្តការរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករ-និយោជិតនៅពេលព្យួរកិច្ចសន្យាការងារ ដោយប្រើប្រាស់កញ្ចប់ថវិកាសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលជំនាញខ្លីរយៈពេលខ្លីដល់កម្មករ-និយោជិត។

**ប្រការ ២៩.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំសំណើសុំទូទាត់ថវិកាបុរេប្រទាន ក្នុងរយៈពេលពី ៤ ទៅ ៦ សប្តាហ៍ បន្ទាប់ពីថ្ងៃបើកថវិកាបុរេប្រទាន ដោយត្រូវភ្ជាប់ជាមួយនូវរបាយការណ៍ និងឯកសារពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងសម្រេចទូទាត់ តាមនីតិវិធីជាធរមាន។

## ជំពូកទី ៨
## ការដោះស្រាយបណ្តឹងតវ៉ា

**ប្រការ ៣០.-**

ការដោះស្រាយបណ្តឹងតវ៉ា សម្រាប់គ្រួសារដែលកំណត់អត្តសញ្ញាណដោយក្រសួងមហាផ្ទៃ និងបើកផ្តល់ជូនដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

ការដោះស្រាយបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងកម្មករ-និយោជិតដែលកំណត់អត្តសញ្ញាណ និងបើកផ្តល់ជូនដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវប្រើប្រាស់យន្តការដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមរយៈលេខទូរសព្ទទាន់ហេតុការណ៍ 1297 ឬក្រុមតេឡេក្រាម (https://t.me/khmerworkerchat) ដែលមានស្រាប់។

**ប្រការ ៣១.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវផ្តល់កិច្ចសហការក្នុងការរៀបចំប្រព័ន្ធទូរសព្ទទំនាក់ទំនងទាន់ហេតុការណ៍ ដើម្បីជាយន្តការក្នុងការដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹងអ្នកទទួលផល និងសាធារណមតិឱ្យបានទាន់ពេលវេលា។

## ជំពូកទី ៩

## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ៣២.-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមទទួលបន្ទុកលើការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជំនួយសង្គមនេះ ដោយផ្អែកតាមក្របខណ្ឌតាមដាន និងវាយតម្លៃ ដែលរៀបចំដោយក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់យន្តការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃចំពោះយន្តការនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គម ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ០២០ សហវ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ១០

## កាលបរិច្ឆេទនៃការបើកផ្តល់

**ប្រការ ៣៣.-**

ការបើកផ្តល់សាច់ប្រាក់ជូនប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព, ប្រជាពលរដ្ឋ និងគ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព, កម្មករ-និយោជិតគោលដៅ, និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដែលស្ថិតក្រោមវិសាលភាពនៃសេចក្តីសម្រេចនេះ ត្រូវចាប់ផ្តើមពីដើមខែមិថុនា ឆ្នាំ២០២១។

## ជំពូកទី ១១

## អវសានបញ្ញត្តិ

**ប្រការ ៣៩.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម, នាយកខុទ្ទកាល័យ, អគ្គលេខាធិការក្រុមប្រឹក្សាគាំពារសង្គម, ប្រធានគ្រប់ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ